រាជធានីភ្នំពេញ ,ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣០ សសរ

### ស្តីពីការបន្ថែមសមាសភាពក្នុងគណៈកម្មការដកហូតអាវុធជាតិផ្ទុះ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២/អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងការប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញសេចក្តីសំរេចលេខ ២៨/សសរ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការដកហូតអាវុធជាតិផ្ទុះ
- ដើម្បីធានាស្ថិរភាព សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម

### សំរេច

**ប្រការ ១ :** ត្រូវបានបន្ថែម ឯកឧត្តម ជា សារិន , លោក ហួត ឈាន និងលោក ឈិន ចំនួនពណ៌ ជាសមាជិកក្នុងគណៈកម្មការដកហូតអាវុធជាតិផ្ទុះនៅរាជធានីភ្នំពេញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ខេត្ត-ក្រុង និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

***